# ព្រះម៉ែធរណីតាមចម្លាក់ និងជំនឿផ្សេងៗ

ព្រះម៉ែធរណីស្គាល់ថាជានាងគង្ហីង ឬជាទេពតំណាងអោយព្រះធរណី(ទឹកដី)នៅក្នុងសង្គមខ្មែរ។ ប៉ុន្តែក្នុងជំនឿភូមា និងឥណ្ឌាវិញ គាត់មានឈ្មោះថា (Vasundhara ឬVasun dari) មានន័យថាទឹកដី[១]។ ព្រះម៉ែក៏មានបង្ហាញក្នុងចម្លាក់ បដិមាទោល នៅតាមប្រាសាទ និងផ្ទាំងគំនូរវត្តអារាមនានាក្នុងស្រុកខ្មែរ ជាពិសេសប្រទេសអាស៊ីអាគ្នេយ៍មួយចំនួនទៀត។ ប៉ុន្តែព្រះម៉ែធរណីប្រទះឃើញមានក្នុងប្រពៃណីជាភាសាសំស្ក្រឹតបុរាណទាំងខ្មែរ ឥណ្ឌា និងភូមា។ គាត់បង្ហាញជារូបភាពដំណាងឱ្យធរណី ដែលយើងប្រទះឃើញមានបន្តក្នុងកិច្ចពិធីផ្សេងក្នុងសង្គមខ្មែរ ឧទាហរណ៍ ឡើងគេហដ្ឋាន អភិសេកព្រះ និងជំនឿលើយ័ន្តជាដើម។ ជាពិសេសព្រះម៉ែ ជាព្រះពោធិសត្វការពារក្នុងពេលដែលផ្ចាញ់មារក្នុងប្រវត្តិព្រះពុទ្ធ។ អត្ថបទបទនេះនឹងពិចារណាលើប្រវត្តិក្នុងការគោរព ចម្លាក់សិល្បៈ សិលាចារឹក និងជំនឿដែលបង្ហាញការគោរពប្រតិបត្តក្នុងកិច្ចពិធីផ្សេងៗក្នុងប្រពៃណីខ្មែរ។

ព្រះម៉ែធរណីនៅបន្តការគោរពប្រតិបត្តខ្លាំងក្នុងជំនឿខ្មែរ ភូមា ឥណ្ឌា និងប្រទេសអាស៊ីអាគ្នេយ៍រហូតដល់បច្ចុប្បន្ន[២]។ អ្នកស្រាវជ្រាវមួយចំនួនបង្ហាញពីភស្តុតាងការគោរពព្រះម៉ែនៅក្នុងអត្ថបទជាភាសាបាលី។ លោកហ្សកសឺដេសបានសំគាល់ពាក្យ paṭhama-sambodhi និងព្រះម៉ែធរណី គឺប្រទះឃើញក្នុងភាសារបាលីពីសតវត្សទី១៤ និង១៦ គ.ស។ ប៉ុន្តែតាមពិតឃើញបង្ហាញច្បាស់លាស់ក្នុងអត្ថបទជាភាសាសំស្ក្រឹត ដូចជានៅក្នុងគម្ពីជាពុទ្ធសាសនាមហាយាននៅប្រទេសចិន[៣] និងក្នុងសិលាចារឹកខ្មែរសម័យមុនអង្គរមកម្ល៉េះ។ ជាពិសេសទៀតនៅក្នុងផ្ទាំងសិល្បៈប្រទេសឥណ្ឌាហ្គង់ដារា (Gangdhara) នៅសតវត្សទី១គ.ស មានបង្ហាញព្រះម៉ែធរណីនៅខាងក្រោមបល្ល័ង្កព្រះពុទ្ធរូប និងប្រទះឃើញនៅហ្គូតា

[១] Guthrie 2001: 8

[២] Tho 2018: 2

[៣] Guthrie, 2001: 8

(Gupta) សតវត្សទី៥គ.ស ក្រោយមកទៀត[៤]។ សិល្បៈព្រះម៉ែធរណីនេះបង្ហាញជាចម្លាក់ស្រដៀងគ្នានៅសង្គមខ្មែរ និងភូមាក្នុងសម័យអង្គរ។ ដូច្នេះព្រះម៉ែធរណីល្បីល្បាញក្នុងទម្រង់ជារូបព្រះពុទ្ធផ្ចាញ់មាក្នុងសិល្បៈឥណ្ឌាតំបូងៗ ហើយប្រហែលមកដល់ភូមា និងខ្មែរពីសវទី១០គ.ស។

សិល្បៈព្រះម៉ែធរណីបង្ហាញស្រដៀងគ្នានៅក្នុងជំនឿខ្មែរ និងភូមា។ ប្រជាជនទាំងពីរបានអនុវត្តន៍ការគោរពព្រះពុទ្ធផ្ចាញ់មារ (bhūmisparśamudrā) ជាមួយរូបព្រះម៉ែធរណី។ ការប្រតិបត្តិព្រះម៉ែធរណីស្រដៀងគ្នាក្នុងសម័យអង្គរ និងបាហ្គាន (Pagan) ចាប់ពីសវទី១០ ដល់ទី១៣ គ.ស។ ប៉ុន្តែមានសិល្បៈព្រះម៉ែធរណីខ្វះបានគោរពក្នុងសម័យកាលផ្សេងៗគ្នា តែមានកាយវិការស្រដៀងគ្នា។ ឧទាហរណ៍រូបនៅជញ្ជាំងប្រាសាទបន្ទាយឆ្មារជ្រុងហោជាង ប្រាសាទតាព្រហ្ម ប្រាសាទជ្រុងកំពែងអង្គរ ហោជាងប្រាសាទបន្ទាយធំ (ទាំងចម្លាក់តូចៗតាមជញ្ជាំង) រូបបង្កាន់ដៃនាគនៅអភិរក្សដ្ឋានអង្គរ (រូបលេខ១-៦)។ ចម្លាក់ហោជាងនៅក្នុងអភិរក្សដ្ឋានអង្គរសតវត្សទី១២គ.ស រូបសំរិទ្ធនៅសារមន្ទីរជាតិភ្នំពេញ (Ga.5473 ស.វទី១៥គ.ស) ស្រដៀងគ្នាទៅនឹងរូបសំរិទ្ធនៅភូមា (លេខN.72) និងកាយវិកាទេពស្រីមួយចំនួនទៀតមកពីសម័យប៉ាហ្គាន(រូបលេខ៧-៨)។ រីឯការបង្ហាញជាម៉ូតសក់វែង និងមុខមាត់ជាស្ត្រីស្រដៀងគ្នាទៅនឹងរូបអប្សរាក្នុងតំបន់អង្គរ និងបាហ្គាន។ តែខុសគ្នាត្រង់ម៉ូតសក់របស់ព្រះម៉ែធរណីបង្ហាញជាលក្ខណៈមានកាយវិការ។

ផ្សេងពីនេះទៀតសិល្បៈព្រះម៉ែបង្ហាញនៅលើបង្គោលសីមា ពពិល និងយ័ន្តដែលបង្ហាញការគោរពខ្លាំងក្នុងជំនឿ និងពិធីផ្សេងៗរបស់ខ្មែរ[៥]។ ដូច្នេះរូបចម្លាក់ ឬជំនឿលើម៉ែធរណីប្រហែលមានតាំងពីមុនសម័យអង្គរ ពីព្រោះព្រះម៉ែធរណីបង្ហាញក្នុងសិល្បៈចិនតាំងពីដើមសតវត្សទី៧គ.សមកម្ល៉េះ[៦]។ តាមសិលាចារឹក K.293-40 និងសិលាចារឹកមុនអង្គរ

---

[៤] Guthrie 2004: 3

[៥] Thompson, 2016: 150-151

[៦] Guthrie, 2004: 124

ក្រាំងព្រះពុទ្ធ K.1413 សរសេរពីព្រះម៉ែធរណីឬនាងគង្ហីង ដែលជាទេពក្នុងសាសនាព្រាហ្មណ៍[៧]។ នាងគង្ហីងមានន័យខ្ញាំងពូកែ ខ្ពង់ខ្ពស់ ដែលប្រើច្រើនក្នុងឋានន្តរនាមរបស់នារី ឬក្សត្រីនៃវណ្ណៈអភិជន ឬរាជវង្សានុវង្ស[៨]។ ក្រោយមកទៀតចម្លាក់ព្រះម៉ែធរណីហាក់ដូចជាពុំសូវមានការពេញនិយមខ្លាំងដូចមុនក្នុងភូមាចាប់ពីសតវត្សទី១៧គ.ស[៩] ដោយបានធ្លាក់ចេញដាច់ពីរូបព្រះពុទ្ធផ្ចាញ់មារនៅលើបង្គោលសីមាជុំវិញព្រះវិហារវិញ[១០]។ ប៉ុន្តែនៅកម្ពុជាគេតែងឆ្លាក់រូបជាប់បល្ល័ង្ក និងនៅក្នុងព្រះវិហាររហូតដល់សម័យបច្ចុប្បន្ន។

លក្ខណៈពិសេសផ្សេងទៀត ព្រះម៉ែធរណី គឺល្បីល្បាញក្នុងពីធីអភិសេកព្រះនៅប្រទេសកម្ពុជា ដែលយើងពុំដែលឃើញអនុវត្តនៅប្រទេសភូមាទេ[១១](រូបលេខ៩)។ នៅប្រទេសកម្ពុជាទាក់ទងនឹងព្រះម៉ែធរណី និងមារ គឺបានសំដែងក្នុងពិធីជាសាច់រឿងនៅតាមជនបទ។ ផ្ចាញ់មារ គឺសំដែងដោយក្រុមក្មេងប្រុស និងស្រីរាំក្នុងពេលធ្វើពីធីអភិសេកព្រះនៅក្នុងវត្តអារាម ឧទាហរណ៍នៅខេត្តបាត់ដំបង និងសៀមរាប។ ដូច្នេះប្រហែលខ្មែរស្គាល់ព្រះម៉ែធរណី និងការសម្តែងតាំងពីសម័យមុនអង្គរមក ហើយបន្តគោរពនៅក្នុងព្រះវិហារ ប៉ុន្តែនៅប្រទេសភូមាឆ្លាក់រូបព្រះម៉ែធរណីនៅខាងក្រៅជុំវិញព្រះវិហារវិញពេលក្រោយៗមក។

ចម្លាក់ព្រះម៉ែធរណីនៅពតិល ដែលខ្មែរប្រើប្រាស់ក្នុងពីធីផ្សេងៗជាពិសេសក្នុងពិធីមង្គលការដូចជា ក្នុងពិធីបង្វិល។ ក្នុងនោះយើងក៏ឃើញរូបព្រះម៉ែធរណីមានសូនជារូបក្នុងពីធីប្រុងពលីផ្សេងៗជាពិសេសពិធីសាងសង់អាគាថ្មី គឺក្នុងន័យខាតបង់អ្វីមួយដើម្បីបានអ្វីមួយថ្មីដែលបញ្ជាក់ពីការផុះដាលចម្រុងចម្រើនទៅមុខ[១២]។

[៧] ហ៊ុន ឈុនតែង ២០២០
[៨] ហ៊ុន ឈុនតែង ២០២០
[៩] Guthrie 2001: 10
[១០] Tho Thon 2018: 2
[១១] Tho  Thon, 2018: 8
[១២] ញឹម សុធារិទ្ធ ២០២០

អត្ថបទដោយ៖ លោក ថូ ថុន

សរុបសេចក្តីមកចម្លាក់ព្រះម៉ែធរណី និងការគោរព គឺមានតាំងពីសម័យមុនអង្គរមកម្ល៉េះ ដោយយើងប្រទះឃើញមានក្នុងសិលាចារឹក។ ចម្លាក់នៅតាមប្រាសាទមួយចំនួនដូចជាតាព្រហ្ម បន្ទាយធំ បន្ទាយឆ្មារ ព្រះខ័ន ប្រាសាទជ្រុង បាយ័ន ដែលរូបមួយចំនួនបង្ហាញនៅលើហោជាងជាមួយព្រះពុទ្ធផ្ចាញ់មារ និងផ្សេងទៀតឆ្លាក់តាមជញ្ជាំងជាមួយព្រះពុទ្ធតូចៗ និងម៉ែធរណី ឬដូចអប្សរាធ្លូតសក់។ រហូតដល់សតវត្សទី១៦ និង១៧គ.ស ទាំងខ្មែរ និងភូមានៅបន្តឆ្លាក់រូបម៉ែធរណី ឬគង្វើងជារូបបដិមាទោលសម្រាប់គោរពបូជា និងមានបន្តសម្តែងក្នុងពិធីផ្សេងៗរហូតដល់បច្ចុប្បន្ន។ ព្រះម៉ែធរណីជាទេពទាក់ទងខ្លាំងជាមួយសាសនាហិណ្ឌូ និងពុទ្ធសាសនា។ រូបចម្លាក់ទោលភាគច្រើនតែងឆ្លាក់ជាមួយរូបក្រពើ និងដៃស្បូតសក់ដំណាងឱ្យម្ចាស់ទឹកដី។ ព្រះម៉ែធរណីមានឈ្មោះច្រើនទាំងក្នុងពុទ្ធសាសនា និងសាសនាហិណ្ឌូនៅប្រទេសឥណ្ឌា។ ព្រះម៉ែធរណីក៏ជាព្រះពោធិសត្វមួយអង្គហៅថា (Vasudhara) នៅក្នុងមហាយាន វជ្រះយាន និងជាទេពព្រះភូមិនៅក្នុងសាសនាហិណ្ឌូទាំងនៅឥណ្ឌា ភូមា និងអាស៊ីអាគ្នេយ៍ផងដែរ។



**រូបលេខ១១៖** រូបព្រះពុទ្ធផ្ចាញ់មារ និងព្រះនាងធរណី (Fournereau L., 1890)



**រូបលេខ១២៖** រូបព្រះពុទ្ធផ្ចាញ់មារ និងព្រះនាងធរណីនៅផ្តែរប្រាសាទតាព្រហ្ម

អត្ថបទដោយ៖ លោក ថូ ថុន



រូបលេខ២៤៖ រូបព្រះពុទ្ធ និងព្រះម៉ែធរណីនៅ



រូបលេខ២៥៖ រូបព្រះពុទ្ធ និងព្រះម៉ែធរណីនៅប្រាសាទព្រះខ័ន



រូបលេខ២៦៖ រូបព្រះពុទ្ធ និងព្រះម៉ែធរណីនៅប្រាសាទតាព្រហ្ម



រូបលេខ២៧៖ រូបព្រះម៉ែធរណីនៅសារមន្ទីរប្រទេសភូមា លេខ N.72។



រូបលេខ២៨៖ រូបព្រះម៉ែធរណីធ្វើពីសំរឹទ្ធសតវត្សទី១៥ នៅសារមន្ទីជាតិភ្នំពេញ



រូបលេខ២៩៖ ពីធីអភិសេកព្រះ និងសម្តែងរឿងទាក់ទងនឹងនាងគង្ហីងឬព្រះម៉ែធរណី។

# ឯកសារយោង


Guthrie, E.
2001. 'Outside the Sima,' *Udaya: 2*, pp.7-18.
Guthrie, E.
2003. 'The Performance of the Maravijaya during Buddhist Consecration Ceremonies,' *Udaya* 6, pp.11-18.
Guthrie, E.
2004. *A Study of the History and Cult of the Buddhist Earth Deity in Mainland Southeast Asia*, Thesis, University of Canterbury, Christchurch, New Zealand,.
Guthrie, E.
2007. 'In Defence of the Nation: the Cult of Nang Thoranee in Northeast Thailand' in I. Harris, ed., *Buddhism, Power, and Political Order*, London and New York: Routledge, pp.168-181.
Thompson, A.
2007. 'Changing Perspectives: Cambodia after Angkor,' in *Millennium of Glory*, H.I Jessup and T. Zephir, eds., Washington: National Gallery of Art.

## ញឹម សុធារិទ

២០២០. "*ប្រុងពលី*" https://ams.com.kh/khmercivilization/detail/574

## ហ៊ិន ឈុនតេង

២០២០. "អំពីពាក្យគង្ហីង" https://ams.com.kh/khmercivilization/12/9/2020.